SV.CY( CAMBODIA )IM-EX CO,.LTD.

# តួនាទី និងការទទួលខុសត្រូវការងារ
# ផ្នែកទិញ

**តួនាទី និងការទទួលខុសត្រូវ:**

ផ្នែកទិញទទួលខុសត្រូវក្នុងការទិញទំនិញ សម្ភារៈ ឧបករណ៍ និងសេវាកម្ម សម្រាប់បម្រើក្នុងក្រុមហ៊ុន ដោយធានាថារាល់ការទិញទាំងអស់ធ្វើឡើងស្របតាមគោលការណ៍ និងនីតិវិធីទិញ របស់ក្រុមហ៊ុន។

តួនាទី:

1. ទទួលខុសត្រូវក្នុងការទិញទំនិញ សម្ភារៈទាំងក្នុងស្រុក និងក្រៅស្រុក។
2. ទទួលខុសត្រូវក្នុងការស្វែងរកអ្នកផ្គត់ផ្គង់ និងធានាថាអ្នកផ្គត់ផ្គង់មានសមត្ថភាព និងសក្ដានុភាពអាចផ្គត់ផ្គង់អោយក្រុមហ៊ុនបាន។
3. ជួបជាមួយអ្នកផ្គត់ផ្គង់ ចរចារ ធ្វើកិច្ចព្រមព្រៀងដើម្បីធានាបានតម្លៃល្អបំផុត។
4. ធានាថារាល់ទំនិញ សម្ភារៈ ដែលទិញនោះ គឺមានគុណភាពខ្ពស់ និងតម្លៃសមរម្យ។
5. ធានាថារាល់ការទិញទំនិញ សម្ភារៈគឺត្រូវបានទិញដរាបណាមានការអនុម័តត្រឹមត្រូវ ពីប្រធានហិរញ្ញវត្ថុ និង នាយកគ្រប់គ្រងទូទៅ និងឬ នាយកប្រតិបត្តិ។
6. ទទួលខុសត្រូវក្នុងការរៀបចំប័ណ្ណបញ្ជាទិញ និងចុះបញ្ជី ការបញ្ជាទិញនៅក្នុងប្រព័ន្ធគណនេយ្យ ERP។ ប័ណ្ណបញ្ជាទិញត្រូវបានរៀបចំទុកដាក់ក្នុងក្រូណូត្រឹមត្រូវសម្រាប់ធ្វើការតាមដានបន្ត។
7. ទទួលខុសត្រូវក្នុងការទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ជាប្រចាំ និងតាមដានការបញ្ជាទិញ និងការផ្គត់ផ្គង់ទំនិញ រហូតដល់អ្នកផ្គត់ផ្គង់ ប្រគល់ ទំនិញគ្រប់ចំនួនតាមការបញ្ជាទិញ។
8. ទទួលខុសត្រូវក្នុងការផ្ដល់ប័ណ្ណបញ្ជាទិញអោយផ្នែកឃ្លាំង និងទំនាក់ទំនងជាប្រចាំសម្រាប់ពត័មានដឹកជញ្ជូនទំនិញ និងការទទួលទំនិញ។
9. ទទួលខុសត្រូវក្នុងការទំនាក់ទំនងអ្នកផ្គត់ផ្គង់នៅពេលមានការប្រគល់ទំនិញមិនគ្រប់ចំនួន ផ្គត់ផ្គង់មុខទំនិញខុសពីការបញ្ជាទិញ ទំនិញខូចគុណភាព ដែលនាំអោយមានការបង្វិលទំនិញ ត្រលប់ទៅអ្នកផ្គត់ផ្គង់វិញជាដើម។

10. ទទួលខុសត្រូវក្នុងការទំនាក់ទំនងជាមួយជាមួយអ្នកផ្គត់ផ្គង់ និងភ្នាក់ងារនាំចូលទំនិញ និងតាមដានស្ថានភាពដឹកជញ្ជូនទំនិញរហូតមកដល់ឃ្លាំងរបស់ក្រុមហ៊ុន។
11. ធានាថារាល់ការផ្គត់ផ្គង់ទំនិញ សម្ភារៈដែលបានទិញត្រូវបានផ្គត់ផ្គង់មកក្រុមហ៊ុនទាន់ពេលវេលា។
12. ទទួលខុសត្រូវក្នុងការធ្វើរបាយការណ៍តាមដានការបញ្ជាទិញ ទំនិញផ្គត់ផ្គង់គ្រប់ចំនួន ទំនិញផ្គត់ផ្គង់ មិនគ្រប់ចំនួន ទំនិញមិនទាន់ផ្គត់ផ្គង់ និងរាយការណ៍ជូនប្រធានហិរញ្ញវត្ថុ និងនាយកគ្រប់គ្រងទូទៅ។
13. ទទួលខុសត្រូវក្នុងការតាមដាន និងធ្វើរបាយការណ៍ ការនាំចូលទំនិញ ដោយផ្ទៀងផ្ទាត់ជាមួយ មុខទំនិញ និងបរិមាណ ដែលមានច្បាប់អនុញ្ញាតនាំចូលរួចហើយ។
14. យល់ដឹងពីនីតិវិធីនាំចូលទំនិញ និងរៀបចំឯកសារនាំចូលទំនិញស្របតាមនីតិវិធីអគ្គនាយកដ្ឋានគយ
15. ស្វែងរក និងទំនាក់ទំនងជាមួយភ្នាក់ងារសេវាករដឹកជញ្ជូន អ្នកផ្គត់ផ្គង់ និមន្ត្រីគយដើម្បីនាំចូលទំនិញ
16. បំពេញការងារផ្សេងៗទៀតទៅតាមការចាត់តាំងរបស់ប្រធានហិរញ្ញវត្ថុ និងនាយកគ្រប់គ្រងទូទៅ។

**តម្រូវការលក្ខខណ្ឌការងារ**

1- បរិញ្ញាប័ត្រផ្នែកគណនេយ្យ / ធនាគារ / ពាណិជ្ជកម្ម / គ្រប់គ្រង រឺសញ្ញាបត្រប្រហាក់ប្រហែល
2- មានបទពិសោធន៍លើការងារក្នុងតួនាទីនេះចាប់ពី ២ ឆ្នាំឡើងទៅ
3- មានចំណេះដឹង/ជំនាញ ផ្នែកគ្រប់គ្រង
4- មានភាពស្មោះត្រង់ ក្លាហាន មានទំនួលខុសត្រូវក្នុងការងារ និងតួនាទី
5- គោរពពេលវេលាអោយបានទៀងទាត់មានភាពឆ្លាតវៃក្នុងការដោះស្រាយបញ្ហា
6- មានផ្នត់គំនិតរៀន និងអភិវឌ្ឍន៍ចំណេះដឹងជាប្រចាំ
7- សម្របខ្លួនធ្វើការងារជាក្រុម និងកែលំអរការងារជាប្រចាំ
8- ចេះប្រកុំព្យូទ័រ MS. Word, Excel, E-mail, and Accounting Software (ERP)

**Interested candidate can send CV and Cover letter to the below emails:**
HR@tmhcambodia.com Tel: (+855 )88 333 5654

Lot #1659. Str. Phnom Penh Hanoi (1019), Banlar Saeat Village, Sangkat Khmuonh, Khan Sen Sok, Phnom Penh, CAMBODIA.